# ព្រះរាជាណាចក្រកម្ពុជា

## គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣
(LASED III)

## ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ (CHPF)
ឧបសម្ព័ន្ធ ៣ នៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)


រៀបចំឡើងដោយ ៖
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)


DRAFT


**ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា**
ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០២០

## ពាក្យកាត់

| | |
|---|---|
| CHPF | ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ |
| CHMP | ផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ |
| ESMF | ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESS | បទដ្ឋានបរិស្ថាន និងសង្គម |
| IP | ជនជាតិដើមភាគតិច |
| IPPF | ក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច |
| IDA | សមាគមអភិវឌ្ឍន៍អន្តរជាតិ |
| ICLT | ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច |
| LASED | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SLC | សម្បទានដីសង្គមកិច្ច |
| CFP | នីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ |

DRAFT

# មាតិកា


សេចក្តីសង្ខេប ........................................ 4
១.សេចក្តីផ្តើម និងគោលបំណង ........................................ 5
២.គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣ ........................................ 6
៣.និយមន័យ និងការអនុវត្តបទប្បញ្ញត្តិច្បាប់ ........................................ 8
៤.សង្គតភាពទៅនឹងក្របខណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក ........................................ 11
៥.បេតិកភណ្ឌវប្បធម៌ក្នុងតំបន់គម្រោង ........................................ 12
៦.វិធានការការពារបេតិកភណ្ឌវប្បធម៌ក្នុងក្នុងគម្រោងដំណាក់កាលទី ៣ ........................................ 15
៦.១ វិធីសាស្ត្រ ........................................ 15
៦.២ វិធានការដាក់លាក់ ........................................ 17


DRAFT

# សេចក្តីសង្ខេប

ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ (CHPF) ត្រូវបានរៀបចំឡើងដើម្បីបំពេញលក្ខខណ្ឌតម្រូវរបស់ធនាគារពិភពលោកចំពោះរដ្ឋាភិបាលកម្ពុជាស្តីពីការអនុវត្តបទដ្ឋានបរិស្ថាន និងសង្គមទី ៨ ដែលជាផ្នែកមួយនៃក្របខណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក។ បទដ្ឋានទី ៨ ត្រូវបានបំផុសសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣ (LASED III) ព្រោះគម្រោងនេះអាចបង្កផលប៉ះពាល់លើធនធានបេតិកភណ្ឌវប្បធម៌ទាំងទម្រង់រូបី និងអរូបីដែលបន្សល់ទុកពីអតីតកាល សម័យមុនអង្គរ និងសម័យអង្គរ និងសម័យបច្ចុប្បន្ន និងអនាគតរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងតំបន់ដែលអាចក្លាយជាទីតាំងគម្រោង។ ធនធានបេតិកភណ្ឌវប្បធម៌ដើរតួនាទីយ៉ាងសំខាន់ ព្រោះវាផ្តល់ព័ត៌មានប្រវត្តិសាស្ត្រ និងជាធនធានសេដ្ឋកិច្ច និងសង្គមសម្រាប់សហគមន៍មូលដ្ឋាន និងសម្រាប់ការអភិវឌ្ឍជាតិ។ ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ចែងពីវិធានការការពារបេតិកភណ្ឌវប្បធម៌ក្នុងវដ្តជីវិតគម្រោង។ ការអនុវត្តក្របខណ្ឌនេះត្រូវបន្សុីគ្នានឹងបទដ្ឋានបរិស្ថាន និងសង្គមទី ៧ របស់ធនាគារពិភពលោក ដែលចែងពីក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិចសម្រាប់គម្រោងដំណាក់កាលទី ៣។ ក្រៅពីនេះ វិធានការសម្រាប់ការអនុវត្តក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ ត្រូវពិចារណាពីបទដ្ឋានបរិស្ថាន និងសង្គមទី ៦ (ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតដោយនិរន្តរភាព) ដែលកត់សម្គាល់ពីតម្លៃសង្គម និងវប្បធម៌នៃតំបន់អភិរក្សជីវចម្រុះដែលទីតាំងគម្រោងស្ថិតនៅក្នុង ឬនៅក្បែរ។ ក្រោមគោលបំណងរួមបញ្ចូលមនុស្សគ្រប់រូប ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌នឹងអនុវត្តតាមបទប្បញ្ញត្តិស្តីពីផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ ដែលត្រូវបានរៀបចំឡើងសម្រាប់គម្រោងដំណាក់កាលទី៣ ដោយអនុលោមតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ១០ (ការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការផ្សព្វផ្សាយព័ត៌មាន)។

DRAFT

## ១.សេចក្តីផ្តើម និងគោលបំណង

1. ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ ចែងពីបទប្បញ្ញត្តិទូទៅសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌ពីផលប៉ះពាល់អវិជ្ជមានដោយសារសកម្មភាពគម្រោងដំណាក់កាលទី ៣ និងគាំទ្រដល់ការអភិរក្សបេតិកភណ្ឌវប្បធម៌ទាំងសម្រាប់សកម្មភាពសម្បទានដីសង្គមកិច្ច (SLC) និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច (ICLT) ក្រោយការកំណត់អត្តសញ្ញាណទីតាំងរួចរាល់។ ក្របខណ្ឌនេះត្រូវបានរៀបចំឡើងដោយអនុលោមតាមបទដ្ឋានបរិស្ថាន និងសង្គមទី ៨ (បេតិកភណ្ឌវប្បធម៌) របស់ធនាគារពិភពលោក។

2. បទដ្ឋានបរិស្ថាន និងសង្គមទី ៨ ទទួលស្គាល់ថា បេតិកភណ្ឌវប្បធម៌ផ្តល់ការផ្សារភ្ជាប់គ្នារវាងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ទាំងក្នុងទម្រង់រូបី និងអរូបី។ បទដ្ឋាននេះកំណត់ពីវិធានការសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌នៅគ្រប់ដំណាក់កាលនៃវដ្តជីវិតគម្រោង (ការវាយតម្លៃបរិស្ថាន និងសង្គម)។ ការរៀបចំ និងអនុវត្តគម្រោងយកចិត្តទុកដាក់បំផុតលើបេតិកភណ្ឌវប្បធម៌។ ការអនុវត្តក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ត្រូវស៊ីសង្វាក់គ្នានឹងក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច ដែលត្រូវបានរៀបចំឡើងដោយអនុលោមតាមបទដ្ឋានបរិស្ថាន និងសង្គមទី ៧ (ជនជាតិដើមភាគតិច) និងកំណត់ពីលក្ខខណ្ឌតម្រូវបន្ថែមសម្រាប់បេតិកភណ្ឌវប្បធម៌ក្នុងបរិបទជនជាតិដើមភាគតិច។ បទដ្ឋានទី ៨ មានភាពពាក់ព័ន្ធនៅចំណុចនេះ ព្រោះសកម្មភាពដែលស្នើឡើងក្នុងគម្រោងដំណាក់កាលទី ៣ អាចប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលលើបេតិកភណ្ឌវប្បធម៌រូបី និងអរូបី និង/ឬលទ្ធភាពប្រើប្រាស់បេតិកភណ្ឌទាំងនោះ។ ក្រៅពីនេះ អាចមានការរកឃើញបេតិកភណ្ឌវប្បធម៌ដែលគេមិនស្គាល់ក្នុងពេលឈូសឆាយសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រខ្នាតតូច។

3. សម្បត្តិបេតិកភណ្ឌវប្បធម៌រូបី (ទីតាំង និងវត្ថុនានា) ដែលបន្សល់ពីសម័យមុនអង្គរ និងសម័យអង្គរ ស្ថិតនៅរាយប៉ាយពាសពេញផ្ទៃប្រទេស។ ឧ. ខេត្តកំពង់ចាម ក្រចេះ តាកែវ និងព្រៃវែង សុទ្ធតែសំបូរដោយទីតាំងមុនសម័យអង្គរ។ ខេត្តសៀមរាប ព្រះវិហារ និងកំពង់ធំ សំបូរដោយទីតាំង និងវត្ថុបុរាណដែលបន្សល់ទុកពីសម័យមុនអង្គរ និងសម័យអង្គរ។ ដង់ស៊ីតេនៃទីតាំង និងវត្ថុបុរាណទាំងនេះមានកម្រិតទាបនៅតំបន់ព្រៃដែលគេរំពឹងថានឹងក្លាយជាទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច។

4. បេតិកភណ្ឌអរូបី ជាពិសេសបេតិកភណ្ឌវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច មានច្រើននៅបណ្តាខេត្តភាគឦសាន ដែលសំបូរដោយសហគមន៍ជនជាតិដើមភាគតិច (មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ក្រចេះ និងព្រះវិហារ)។ គម្រោងដំណាក់កាលទី ៣ នឹងជួយដល់សហគមន៍ជនជាតិដើមភាគតិចក្នុងបណ្តាខេត្តទាំងនេះលើដំណើរការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងផ្តល់ការគាំទ្រដល់របរចិញ្ចឹមជីវិត។

5. ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌មានគោលបំណង ៖

- បញ្ចៀសទីតាំងបេតិកភណ្ឌវប្បធម៌ដែលគេស្គាល់ (រួមបញ្ចូលទាំងទីតាំងបុរាណវិទ្យា និងទីតាំងប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច) ទៅតាមភាពចាំបាច់ និងអាចអនុវត្តបាន។

DRAFT

- ក្នុងករណីដែលមិនអាចបញ្ចៀសបាន នឹងមានគ្រប់គ្រងទីតាំងបេតិកភណ្ឌវប្បធម៌ និងវត្ថុនានា ដោយអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងច្បាប់ និងបទប្បញ្ញត្តិនានា និងឆ្លងកាត់ការពិគ្រោះយោបល់ជាមួយមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំដោយអនុលោមតាមតាមបទដ្ឋានបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោកស្តីពីរបៀបវាយតម្លៃ ចងក្រងឯកសារ និងគ្រប់គ្រងលទ្ធផលរកឃើញបេតិកភណ្ឌវប្បធម៌
- រៀបចំនីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ ដើម្បីកាត់បន្ថយផលប៉ះពាល់លើធនធានវប្បធម៌ដែលមិនទាន់បានកំណត់អត្តសញ្ញាណ ដែលអាចប្រទះឃើញក្នុងវដ្តគម្រោង
- ពង្រឹងទំនាក់ទំនងជាមួយសហគមន៍រងផលប៉ះពាល់ និងលុបបំបាត់បណ្តឹងតវ៉ារបស់សហគមន៍ដែលពាក់ព័ន្ធនឹងផលប៉ះពាល់លើធនធានវប្បធម៌ និង
- កំណត់ពីតួនាទី និងការទទួលខុសត្រូវលើការអនុវត្តក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ និងផែនការតាមទីតាំង។

## ២.គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣

6. គម្រោងដំណាក់កាលទី ៣ ជាគម្រោងបន្តពីគម្រោងដំណាក់កាលដំបូង និងគម្រោងដំណាក់កាលទី ២។ គម្រោងទាំងនេះបានផ្តល់ការគាំទ្រដល់ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់ឃុំរបស់រាជរដ្ឋាភិបាលកម្ពុជា។ គម្រោងដំណាក់កាលទី ៣ នឹងគាំទ្រដល់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច តាមរយៈសិទ្ធិកាន់កាប់ដីធ្លី និងជំនួយហេដ្ឋារចនាសម្ព័ន្ធជនបទពាក់ព័ន្ធ និងសកម្មភាពចិញ្ចឹមជីវិត។ គម្រោងដំណាក់កាលទី ៣ នឹងផ្តល់ជំនួយលើការដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចថ្មី ការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងការដាក់ពាក្យសុំជំនួយអភិវឌ្ឍន៍ដល់សហគមន៍ជនជាតិដើមភាគតិចដែលទទួលបានប័ណ្ណកម្មសិទ្ធិ ដោយផ្អែកតាមគោលការណ៍ "អ្នកមកមុន បានមុន"។

7. ក្នុងសមាសភាគទី ១ គម្រោងដំណាក់កាលទី ៣ នឹងផ្តល់ការគាំទ្រដល់ការកំណត់អត្តសញ្ញាណ និងការបង្កើតផែនការអភិវឌ្ឍន៍សម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ផែនការប្រើប្រាស់ដីនឹងត្រូវបានរៀបចំឡើងសម្រាប់រក្សាការពារធនធានទឹកធម្មជាតិ គម្របព្រៃឈើ យកចិត្តទុកដាក់លើបណ្តាញប្រឡាយបង្ហូរទឹកធម្មជាតិ ឬអាងទឹក ដើម្បីធានាការប្រើប្រាស់ដីធ្លីដែលកាត់បន្ថយហានិភ័យមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ ដូចជា គ្រោះរាំងស្ងួត ឬគ្រោះទឹកជំនន់។ សកម្មភាពសំខាន់ៗ ៣ ដែលត្រូវអនុវត្តក្នុងសមាសភាគនេះមានដូចតទៅ។ ទីមួយ គឺការរៀបចំផែនការដោយមានការចូលរួមសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចសម្រាប់ទីតាំងថ្មីៗ។ ទីពីរ គឺការកំណត់អត្តសញ្ញាណ ការកំណត់អាទិភាព និងការរៀបចំផែនការសម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទ រួមទាំងការប្រមូលទិន្នន័យដើមគ្រាពាក់ព័ន្ធសម្រាប់គម្រោង។ ទីបី គឺការដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីក្នុងទីតាំងសម្បទានដីស

DRAFT

ង្គមកិច្ចដល់អ្នកដែលមានលក្ខណៈសម្បត្តិទទួលបានដីធ្លី និងប័ណ្ណកម្មសិទ្ធិដីសមូហភាពក្នុងសហគមន៍ជនជាតិដើមភាគតិច។

8. សមាសភាគទី ២ គឺការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគមន៍។ បន្ទាប់ពីការជ្រើសរើសការវិនិយោគហេដ្ឋារចនាសម្ព័ន្ធជាអាទិភាព និងអាចអនុវត្តទៅបាននៅទីតាំងគម្រោងថ្មីក្នុងសមាសភាគទី ១ សមាសភាគទី ២ នឹងផ្តោតលើការផ្តល់ហិរញ្ញប្បទានដល់ការអនុវត្តការវិនិយោគ ដូចជា ការផ្តល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសហគមន៍ដែលផ្តល់ផលិតភាព/ពាក់ព័ន្ធនឹងសេដ្ឋកិច្ច និងសង្គមកិច្ច (ឧ. ផ្លូវជនបទ ប្រព័ន្ធបង្ហូរទឹកពីចំហៀង កងលូ ការផ្គត់ផ្គង់ទឹក និងមូលដ្ឋានអនាម័យ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច អគារសិក្សា ផ្ទះគ្រូ ប៉ុស្តិ៍សុខភាព និងមជ្ឈមណ្ឌលសហគមន៍។ល។)។ គេរំពឹងថា គម្រោងនឹងវិនិយោគច្រើនបំផុតលើការតភ្ជាប់បណ្តាញដឹកជញ្ជូនដែលផ្តល់ប្រយោជន៍លើសពីអ្នកទទួលផលផ្ទាល់ពីគម្រោង (ឃុំទាំងមូល និងតំបន់ជុំទូលាយ)។ ការវិនិយោគបន្ទាប់ផ្តោតលើការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតំបន់រស់នៅ និងគម្រោងធារាសាស្ត្រខ្នាតតូចដែលមាននិរន្តរភាព និងធន់នឹងការប្រែប្រួលអាកាសធាតុ អាស្រ័យលើតម្រូវការរបស់សហគមន៍។

9. សមាសភាគទី ៣ គឺការផ្តល់ជំនួយអភិវឌ្ឍន៍កសិកម្ម និងរបរចិញ្ចឹមជីវិតដល់សហគមន៍ក្នុងទីតាំងសម្បទានដីសង្គមកិច្ច និងសហគមន៍ដែលត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ សមាសភាគនេះនឹងជួយដល់ដំណើរការតាំងទីលំនៅរបស់គ្រួសារអ្នកទទួលផល ការកសាងធនធានសង្គម-សេដ្ឋកិច្ច (ក្រុមអ្នកផលិត/សហករណ៍) និងការអភិវឌ្ឍប្រព័ន្ធផលិតកម្មកសិកម្មដោយផ្អែកតាមតម្រូវការទីផ្សារ និងធន់នឹងការប្រែប្រួលអាកាសធាតុ។ សកម្មភាពទាំងនេះរួមមានការផ្តល់ជំនួយដល់ ១) ការតាំងទីលំនៅថ្មីសម្រាប់អ្នកដែលទើបទទួលបានដីធ្លី និងជំនួយលើការរៀបចំដីធ្លីសម្រាប់ការដាំដំណាំគម្របជាលើកដំបូង ២) ការអនុវត្តយុទ្ធសាស្ត្រសេវាកសិកម្មគ្រប់ជ្រុងជ្រោយ ដោយផ្តោតសំខាន់លើបច្ចេកទេសធ្វើកសិកម្មដែលធន់នឹងអាកាសធាតុ ៣) ការបង្កើត និង/ឬពង្រឹងអង្គការកសិករលើសកម្មភាពផលិតកម្ម និងការធ្វើទីផ្សារ និងក្រុមចំណាប់អារម្មណ៍ផ្សេងទៀតក្នុងសហគមន៍ និង ៤) ការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍសហគមន៍ ដើម្បីពង្រីកគំនិតផ្តួចផ្តើមជោគជ័យក្នុងមូលដ្ឋាន។

10. ផ្អែកតាមលក្ខណៈ ទំហំ និងទីតាំងរបស់អនុគម្រោងក្នុងគម្រោងដំណាក់កាលទី ៣ គេរំពឹងថា ផលប៉ះពាល់នៃសកម្មភាពគម្រោងលើបេតិកភណ្ឌវប្បធម៌រូបី (ទីតាំង និងវត្ថុនានា) នឹងមានកម្រិតពីទាបទៅមធ្យម។ ខណៈដែលទីតាំងសម្បទានដីសង្គមកិច្ច ត្រូវបានរំពឹងថានឹងស្ថិតក្នុងតំបន់ដែលមិនសូវមានបេតិកភណ្ឌវប្បធម៌ សកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពចិញ្ចឹមជីវិតប្រហែលជាធ្វើឡើងក្នុងតំបន់ដែលមានបេតិកភណ្ឌវប្បធម៌រូបី និងអរូបី។ ក្រៅពីនេះ ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ការគាំទ្រដល់របរចិញ្ចឹមជីវិត និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនៅទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច អាចបង្កផលប៉ះពាល់អវិជ្ជមានលើបេតកិភណ្ឌរូបី និងអរូបីរបស់សហគមន៍ជនជាតិដើមភាគតិច ជាពិសេសកន្លែងសក្តិសិទ្ធ និងតំបន់ដែលមានសារៈសំខាន់សម្រាប់សកម្មភាពវប្បធម៌ កំសាន្ត និងសោភណ្ឌភាព ដែលផ្តល់សុខុមាលភាពសង្គម និងអត្ថប្រយោជន៍មិនមែនសម្ភារដល់សហគមន៍។ ដំណើរការជ្រើសរើសទីតាំងនឹងរួមបញ្ចូលនីតិវិធីកំណត់អត្តសញ្ញាណបេតិកភណ្ឌវប្បធម៌រូបី និងអរូបីដែលអាចរងផលប៉ះពាល់ក្នុងពេលអនុវត្តគម្រោងនៅកម្រិតទីតាំង ព្រមទាំងដំណើរការពិនិត្យបឋម និង

DRAFT

វាយតម្លៃ ដែលបន្ស៊ីគ្នានឹងក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ដើម្បីកាត់បន្ថយផលប៉ះពាល់ និងការខាតបង់ជាអតិបរមា។

## ៣.និយមន័យ និងការអនុវត្តបទប្បញ្ញត្តិច្បាប់

11. **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់ការការពារយ៉ាងពេញលេញលើវប្បធម៌ និងបេតិកភណ្ឌជាតិគ្រប់ប្រភេទ។ មាត្រា ៦៩ ចែងថា "រដ្ឋមានកាតព្វកិច្ចថែរក្សា និងពង្រីកវប្បធម៌ជាតិ។ រដ្ឋមានកាតព្វកិច្ចថែរក្សា និងការពារប្រាសាទ បុរាណវត្ថុ សិល្បៈបុរាណ និងកែលម្អរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ។ មាត្រា ៧០ ចែងថា "បទល្មើសទាំងឡាយដែលប៉ះពាល់ ឬទាក់ទងនឹងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌសិល្បៈ ត្រូវផ្តន្ទាទោសជាទម្ងន់"។ មាត្រា ៧១ ចែងថា "បេតិកភណ្ឌវប្បធម៌ក៏ដូចជា បេតិកភណ្ឌដែលបានបញ្ចូលជាបេតិកភណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹត ដែលមិនឱ្យមានសកម្មភាពយោធា"។

12. **ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ (១៩៩៦)** មានបទប្បញ្ញត្តិសម្រាប់ "ការថែរក្សាការពារបេតិកភណ្ឌវប្បធម៌ និងជាតិ និងសម្បត្តិវប្បធម៌ទូទៅ ប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូលដោយខុសច្បាប់"។ ច្បាប់នេះចែងថា "នៅពេលកំពុងដំណើរការងារផ្សេងៗ ឬសកម្មភាពផ្សេងៗទៀត ហើយបានជួបប្រទះសម្បត្តិវប្បធម៌ ដូចជា ប្រាសាទបែកបាក់ វត្ថុបុរាណ សំណល់ផ្ទះសម្បែងបុរាណ ទីបញ្ចុះសពបុរាណ សិលាចារឹក ឬសម្បត្តិវប្បធម៌ដែលទាក់ទងដល់បុរេប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យា ឬក៏សាខាដទៃទៀតនៃវិទ្យាសាស្ត្រ ដែលសិក្សាពីអតីតកាល ឬមនុស្សសាស្ត្រ អ្នកដែលបានប្រទះឃើញសម្បត្តិទាំងនេះ និងម្ចាស់អចលនវត្ថុ ត្រូវតែបញ្ឈប់ការងារ ឬសកម្មភាពនោះ រួចរាយការណ៍ជាបន្ទាន់"។ អាជ្ញាធរអាចប្រកាសឱ្យផ្អាកការងារជាបណ្តោះអាសន្ន និងចាត់វិធានការពារ។ ក្រៅពីនេះ ត្រូវចាត់វិធានការអេចិន្ត្រៃយ៍ពាក់ព័ន្ធនឹងការប្រទះឃើញដោយចៃដន្យ។ យោងតាមច្បាប់នេះ ការរាយការណ៍គឺទៅកាន់ភ្នាក់ងារនគរបាល ហើយនគរបាលបញ្ជូនរបាយការណ៍ទៅរដ្ឋាភិបាលថ្នាក់ខេត្ត។

13. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាស្ថាប័នទទួលខុសត្រូវលើបេតិកភណ្ឌវប្បធម៌ជាតិ ចំណែកមន្ទីរវប្បធម៌ខេត្តជាស្ថាប័នអនុវត្តន៍ការការពារបេតិកភណ្ឌវប្បធម៌ (នៅក្រៅតំបន់អង្គរ/ខេត្តសៀមរាប ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា)។ ក្រៅពីនេះ មានសារៈមន្ទីរមូលដ្ឋាននៅតាមខេត្ត និងស្រុក ដែលចូលរួមការពារបេតិកភណ្ឌវប្បធម៌យ៉ាងសកម្ម។ មន្ទីរវប្បធម៌ស្រុកមិនសូវមានតួនាទីច្រើនទេ។

14. ច្បាប់នេះបានកំណត់ជំហាន ២ សម្រាប់ការការពារ ៖ បញ្ជីសារពើភណ្ឌ និងចំណាត់ថ្នាក់។ កន្លងមកបេតិកភណ្ឌវប្បធម៌ស្ថិតក្នុងដំណាក់កាលបញ្ជីសារពើភណ្ឌ។ មន្ទីរវប្បធម៌ខេត្តជាអ្នកធ្វើបញ្ជីសារពើភណ្ឌ ហើយបញ្ជីសារពើភណ្ឌថ្នាក់ជាតិពេញលេញត្រូវបានរៀបចំឡើងនៅឆ្នាំ ២០០៦។ សារៈមន្ទីរមូលដ្ឋាន ឬគម្រោងនានាក៏រៀបចំបញ្ជីសារពើភណ្ឌមួយចំនួនផងដែរ។ មន្ទីរវប្បធម៌ និងសារៈមន្ទីរមិនសូវមានធនធានច្បាស់លាស់ទេ ប៉ុន្តែជាអ្នកធ្វើ

DRAFT

ទំនាក់ទំនងផ្ទាល់ជាមួយសហគមន៍មូលដ្ឋាន ដើម្បី ក) បន្តរៀបចំបញ្ជីសារពើភណ្ឌនៅមូលដ្ឋាន និង ខ) កសាងការយល់ដឹងរបស់មហាជន និងជូនដំណឹងដល់មហាជនពីភារកិច្ចរាយការណ៍ពីវត្ថុរកឃើញ។

15. គោលនយោបាយស្តីពីបេតិកភណ្ឌវប្បធម៌ដែលអនុវត្តដោយមន្ទីរវប្បធម៌ និងសារៈមន្ទីរ គ្របដណ្តប់លើបេតិកភណ្ឌបុរាណវិទ្យា និងបេតិកភណ្ឌវប្បធម៌ជនជាតិដើមភាគតិច។ ក្នុងករណីទីពីរ ភូមិមួយចំនួនត្រូវបានកត់ត្រាថាសំបូរដោយបេតិកភណ្ឌវប្បធម៌។ សកម្មភាពរបស់ស្ថាប័នទាំងនេះមានតិចតួចទៅតាមទំហំធនធាន និងគ្របដណ្តប់តែលើ "ភូមិអាទិភាព" មួយចំនួនតូចប៉ុណ្ណោះ។

16. កិច្ចខិតខំប្រឹងប្រែងទាំងនេះបានផ្តល់ការយល់ដឹងមធ្យមដល់សហគមន៍ និងមានការរាយការណ៍ពីវត្ថុរកឃើញមួយចំនួន។ ច្បាប់នេះចែងពីការផ្តល់រង្វាន់ដល់អ្នកប្រទះឃើញវត្ថុបុរាណ ប៉ុន្តែការផ្តល់រង្វាន់មានតិចតួចប៉ុណ្ណោះ (ឧ. ចំណាយលើការដឹកជញ្ជូនពីភូមិទៅខេត្ត)។ ការជឿថា ការទុករូបចម្លាក់ក្នុងផ្ទះអាចផ្តល់សំណាងអាក្រក់ បានរួមចំណែកធ្វើឱ្យប្រជាជនមូលដ្ឋានរាយការណ៍ពីវត្ថុរកឃើញ។ អាជ្ញាធរឃុំក៏បានដឹងពីសក្តានុពលសេដ្ឋកិច្ចនៃបេតិកភណ្ឌវប្បធម៌សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ផងដែរ ប៉ុន្តែការជួញដូរវត្ថុដែលរកឃើញ នៅតែកើតឡើងជាធម្មតា។

17. ពាក់ព័ន្ធនឹងគោលនយោបាយដីធ្លី ធៀបនឹងបេតិកភណ្ឌវប្បធម៌ ច្បាប់នេះចែងថា "ការចុះបញ្ជីសារពើភណ្ឌ គឺជាការកត់ត្រាបញ្ចូលនូវសម្បត្តិវប្បធម៌សាធារណៈ ឬឯកជន"។ រដ្ឋបាលដីធ្លីបច្ចុប្បន្នកំណត់ថា មិនអនុញ្ញាតឱ្យមានការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនៅលើទីតាំងចុះបញ្ជីសារពើភណ្ឌឡើយ។ មានន័យថា ការពិនិត្យបឋមលើបេតិកភណ្ឌ ដែលបន្ស៊ីគ្នានឹងក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម សម្រាប់គម្រោងដំណាក់កាលទី៣ ត្រូវធ្វើឡើងមុនពេលបែងចែកដីដល់គ្រួសារនីមួយៗ ដើម្បីធ្វើយ៉ាងណាឱ្យការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីក្រោយរយៈពេល ៥ ឆ្នាំមិនចោទជាបញ្ហា។

18. **អនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាព**-នីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (២០០៩) កំណត់ពីនីតិវិធី ប្រភេទដី និងស្ថាប័នរដ្ឋដែលពាក់ព័ន្ធក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព។ មាត្រា ៦ នៃអនុក្រឹត្យនេះកំណត់ពីដី ៥ ប្រភេទ ដែលត្រូវអាចបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ៖ ១) ដីលំនៅដ្ឋាន ២) ដីព្រៃអារក្ស ៣) ដីកប់ខ្មោច ៤) ដីធ្វើកសិកម្មជាក់ស្តែង និង ៥) ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ។ មាត្រាទី ៦ ថែមទាំងបានបញ្ជាក់ថា ទំហំដីព្រៃអារក្ស និងដីកប់ខ្មោច មានទំហំសរុបមិនលើស ០៧ ហិចតា។ មាត្រា ៨ នៃអនុក្រឹត្យនេះ លើកឡើងពីសិទ្ធិរបស់ជនជាតិដើមភាគតិចលើប្រភេទដីផ្សេងទៀត ដូចជា ដីព្រៃឈើ និងកន្លែងប្រើប្រាស់ទឹក ប៉ុន្តែត្រូវអនុវត្តតាមវិធាន និងបទប្បញ្ញត្តិរបស់ស្ថាប័នសាមីដែលមានអាណត្តិកាន់កាប់ធនធានទាំងនោះ។ អនុក្រឹត្យនេះរៀបរាប់ពីការណែនាំ និងឯកសារសំខាន់ៗដែលសហគមន៍ជនជាតិដើមភាគតិចគួរមាននៅពេលដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។

19. **មាត្រា ១៥ នៃច្បាប់ភូមិបាល ២០០១** ចែងថា បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងវិទ្យាសាស្ត្ររាប់បញ្ចូលជាសម្បត្តិសាធារណៈរបស់រដ្ឋ។ មាត្រា ៥ នៃច្បាប់ភូមិបាលឆ្នាំ ១៩៩២ ចែងថា មិនឱ្យមានសិទ្ធិជាឯកជនក្នុងមណ្ឌលបេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រឡើយ។



DRAFT

20. **ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (១៩៩៤)** ចែងថា ទីតាំងបុរាណវិទ្យា និងប្រវត្តិសាស្ត្រជាតំបន់សាធារណៈ។

21. **អនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ (២០០៥)** បានធ្វើចំណាត់ថ្នាក់ "បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ" ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលត្រូវមានការការពារយ៉ាងតឹងរ៉ឹង និងមិនអាចប្រើប្រាស់សម្រាប់គោលបំណងអភិវឌ្ឍន៍ណាមួយ រួមទាំងសម្រាប់គោលបំណងសម្បទានដីសង្គមកិច្ច។ ផ្អែកតាមអនុក្រឹត្យនេះ **សេចក្តីសម្រេចលេខ ៥២ ស្តីពីការបញ្ចូលឯកសារលក្ខណៈវិនិច្ឆ័យក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ (២០០៦)** ចែងថា "ប្រសិនបើរកឃើញបេតិកភណ្ឌនៅក្នុង ឬនៅលើដីជាកម្មសិទ្ធិរបស់បុគ្គលឯកជន ហើយការដកយកបេតិកភណ្ឌចេញពីដីនោះ មិននាំឱ្យធ្លាក់តម្លៃ ឬអស់តម្លៃនៃបេតិកភណ្ឌនោះទេ ត្រូវដកយកបេតិកភណ្ឌចេញពីដីកម្មសិទ្ធិឯកជននោះ ប៉ុន្តែបើការដកយកបេតិកភណ្ឌចេញពីដីនោះនឹងនាំឱ្យធ្លាក់ចុះតម្លៃ ឬអស់តម្លៃនៃបេតិកភណ្ឌ ជាចាំបាច់ត្រូវរក្សាបេតិកភណ្ឌទុកលើទីតាំងដដែល ហើយត្រូវចេញបទបញ្ជា ឬលិខិតបទដ្ឋានគតិយុត្តិដើម្បីកម្រិតសិទ្ធិប្រើប្រាស់ដីនោះត្រឹមកម្រិតជាក់លាក់ដែលមិនឱ្យប៉ះពាល់ ខូចខាតបេតិកភណ្ឌនោះ ឬប្រកាសដីនោះជាកម្មវត្ថុនៃការដកហូតតាមផ្លូវច្បាប់ ដើម្បីប្រយោជន៍សាធារណៈដោយមានផ្តល់សំណងសមរម្យ និងយុត្តិធម៌ជាមុន។ ដីដែលបានដកហូតនោះត្រូវចាត់ទុកជាដីសាធារណៈរបស់រដ្ឋ"។

22. **ច្បាប់ស្តីពីព្រៃឈើ ២០០២** អនុញ្ញាតឱ្យរាជរដ្ឋាភិបាលកម្ពុជាកំណត់យកផ្នែកណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលជាតំបន់មជ្ឈដ្ឋានពិសេស ឬមានតម្លៃផ្នែកវិទ្យាសាស្ត្រ វប្បធម៌ ទេសចរណ៍ ឬជាតំបន់អភិរក្សជីវចម្រុះ និងទឹក ជាព្រៃការពារ (មាត្រា ២២)។ ច្បាប់នេះទទួលស្គាល់ការប្រើប្រាស់ និងការអនុវត្តជាប្រពៃណីរបស់សហគមន៍មូលដ្ឋានជាព្រៃការពារដែលបម្រើឱ្យគោលបំណងវប្បធម៌ ៖ "ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលស្គាល់ព្រៃពាក់ព័ន្ធជំនឿសាសនារបស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុង ឬក្បែរព្រៃនោះទុកជាព្រៃការពារសម្រាប់គោលបំណងសាសនា វប្បធម៌ ឬអភិរក្ស" (មាត្រា ៤៥)។

23. **ប្រកាសឆ្នាំ ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត/ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ** ចែងថា "មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត/ក្រុង មានតួនាទី និងភារកិច្ចការពារធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ និងជួសជុលថែទាំ ប្រើប្រាស់សំណង់អគារ សំណង់ការ្យ និងបេតិកភណ្ឌក្នុងខេត្តក្រុង"។

24. **សេចក្តីប្រកាសលេខ ០៦ របស់គណៈរដ្ឋមន្ត្រី** ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី ហាមឃាត់សិទ្ធិឯកជនលើទីតាំងបេតិកភណ្ឌវប្បធម៌។ សេចក្តីប្រកាសនេះមានគោលបំណងការពារបេតិកភណ្ឌវប្បធម៌ពីការប្រើប្រាស់សម្រាប់គោលបំណងអភិវឌ្ឍន៍ ក្រៅតែពីការអភិរក្ស និងការការពារដែលបម្រើឱ្យផលប្រយោជន៍វប្បធម៌។

25. **ឯកសារគោលនយោបាយស្តីពីសម្បទានដីសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០២ ចែងថា** "ការរៀបចំបទប្បញ្ញត្តិសម្រាប់ការផ្តល់សម្បទានដីសង្គមកិច្ច ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាជាកញ្ចប់ទាក់ទង

នឹងការគ្រប់គ្រងដីរដ្ឋ។ មុននឹងផ្តល់ដីសម្រាប់គោលបំណងសង្គមកិច្ច ដីរដ្ឋត្រូវតែបានធ្វើអត្តសញ្ញាណកម្ម ធ្វើចំណាត់ថ្នាក់ និងមានផែនការប្រើប្រាស់ជាមុន។ ដីរដ្ឋគឺរួមមានព្រៃឈើ ផ្លូវទឹក ផ្លូវថ្នល់ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្សេងទៀត ដីឧទ្យាន តំបន់ការពារ ទីតាំងមរតកវប្បធម៌ សេវាសាធារណៈនានា និងតំបន់ប្រើប្រាស់សម្រាប់គោលដៅយោធាក៏ដូចជាតំបន់ដែលមិនបានប្រើប្រាស់ផងដែរ"។

## ៤.សង្គតភាពទៅនឹងក្របខណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក

26. ក្របខណ្ឌបរិស្ថាន និងសង្គម (ESF) របស់ធនាគារពិភពលោកចែងពីលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទាំង ១០។ បទដ្ឋានបរិស្ថាន និងសង្គមទី ៨ តម្រូវឱ្យអ្នកខ្ចីរៀបចំក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ (CHPF) សម្រាប់ជាយន្តការការពារ និងទប់ស្កាត់ការបាត់បង់ ឬខូចខាតធនធានវប្បធម៌រូបី និងអរូបី ក្នុងវដ្តគម្រោងទាំងមូល។ បទដ្ឋានបរិស្ថាន និងសង្គមទី ៨ កំណត់ថា បេតិកភណ្ឌវប្បធម៌រូបីរួមបញ្ចូលទាំងចលនវត្ថុ និងអចលនវត្ថុ ទីតាំង សំណង់ ក្រុមសំណង់ និងលក្ខណៈធម្មជាតិ និងទេសភាព ដែលមានសារៈសំខាន់ផ្នែកបុរាណវិទ្យា បាសាណីភូតវិទ្យា ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម សាសនា សោភណ្ឌភាព ឬសារៈសំខាន់ផ្នែកវប្បធម៌ផ្សេងទៀត។ ធនាគារពិភពលោកទទួលស្គាល់ថា គម្រោងអភិវឌ្ឍន៍ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក គួរបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់លើទីតាំង ឬវត្ថុទាំងឡាយណាដែលមានសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រ សាសនា សោភណ្ឌភាព ឬសារៈសំខាន់ផ្នែកវប្បធម៌ផ្សេងទៀត។

27. **ក្របខណ្ឌគតិយុត្តិនៅកម្ពុជាភាគច្រើនស៊ីសង្វាក់គ្នានឹងបទដ្ឋានបរិស្ថាន និងសង្គមទី ៨ របស់ធនាគារពិភពលោក** ជាពិសេសច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ (១៩៩៦) អនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាព សេចក្តីប្រកាសរបស់គណៈរដ្ឋមន្ត្រីលេខ ០៦។ យ៉ាងណាមិញ ក្របខណ្ឌថ្នាក់ជាតិមិនស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹងលក្ខខណ្ឌតម្រូវនៃបទដ្ឋានបរិស្ថាន និងសង្គម លើចំណុចដូចខាងក្រោម ៖

- ក្របខណ្ឌគតិយុត្តិផ្តោតសំខាន់លើបេតិកភណ្ឌវប្បធម៌រូបី ប៉ុន្តែមិនសូវផ្តោតលើបេតិកភណ្ឌវប្បធម៌អរូបីឡើយ។
- ក្របខណ្ឌគតិយុត្តិមិនដាក់បញ្ចូលលក្ខខណ្ឌតម្រូវនៃបទដ្ឋានបរិស្ថាន និងសង្គមទី ៨ (ការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ)។

28. ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ ត្រូវបានរៀបចំឡើងដើម្បីលុបបំបាត់ចំណុចខ្វះខាតទាំងនេះ (មើលខ្លឹមសារលម្អិតក្នុងផ្នែក ៥.២)។ ក្របខណ្ឌនេះគ្របដណ្តប់លើលំហវប្បធម៌ផ្សេងៗ (ទាំងរូបី និងអរូបី) សម្រាប់សហគមន៍ជនជាតិដើមភាគតិច។ លំហទាំងនេះរួមដីដូនតា ដីព្រៃ វាលស្មៅ ដីលំនៅដ្ឋាន និងកសិកម្ម កន្លែងបរបាញ់សត្វ ទីគោរពបូជា និងដីដែលសហគមន៍វប្បធម៌ជនជាតិដើមភាគតិចលែងរស់នៅ ប៉ុន្តែនៅមានភាពពាក់ព័ន្ធនឹងប្រពៃណីរបស់ពួកគេ ជាពិសេសតំបន់សត្វដើររកចំណីរបស់សហគមន៍ជនជាតិដើមភាគតិចដែលនៅបន្តធ្វើកសិកម្មបែបពនេចរណ៍។

29. ការអនុវត្តបទដ្ឋានបរិស្ថាន និងសង្គមទី ៨ មានភាពពាក់ព័ន្ធបំផុតទៅនឹងបទដ្ឋានបរិស្ថាន និងសង្គមទី ៧ ដែលផ្តល់ការណែនាំលម្អិតក្នុងការបញ្ចៀស កាត់បន្ថយជាអតិបរមា និង/ឬសម្រាលផលប៉ះពាល់អវិជ្ជមានរបស់គម្រោងលើសហគមន៍ជនជាតិដើមភាគតិច និងធ្វើការប៉ះប៉ូវលើផលប៉ះពាល់។ បទដ្ឋានបរិស្ថាន និងសង្គមទី ៧ មានគោលបំណងទទួលស្គាល់ គោរព និងអភិរក្សវប្បធម៌ ចំណេះដឹង និងការអនុវត្តរបស់សហគមន៍ជនជាតិដើមភាគតិច និងផ្តល់ឱកាសឱ្យពួកគេសម្របខ្លួនទៅនឹងការប្រែប្រួលស្ថានភាពតាមរបៀប និងក្នុងក្របខណ្ឌពេលវេលាដែលពួកគេអាចទទួលយកបាន។ បទដ្ឋានបរិស្ថាន និងសង្គមទី ៧ តម្រូវឱ្យមានការទទួលបានការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ (FPIC) ពីជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ក្នុងកាលៈទេសៈមួយចំនួន ដូចជា នៅពេលដែលគម្រោងអាចបង្កផលប៉ះពាល់ធំធេងលើបេតិកភណ្ឌវប្បធម៌របស់ពួកគេដែលមានសារៈសំខាន់ចំពោះ អត្តសញ្ញាណ និង/ឬវប្បធម៌ ពិធីបុណ្យ ឬជំនឿក្នុងជីវិតរស់នៅរបស់ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ទាំងនោះ។

30. បទដ្ឋានបរិស្ថាន និងសង្គមទី ៨ តម្រូវឱ្យអ្នកខ្ចីពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌ដែលអាចរងផលប៉ះពាល់ដោយសារគម្រោង រួមទាំងភាគីដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីចំណាប់អារម្មណ៍ផ្សេងទៀត ដូចជា អ្នកមានកាតព្វកិច្ចក្នុងមូលដ្ឋាន និងអ្នកកាន់ប្រពៃណីរបស់ជនជាតិដើមភាគតិចដែលអាចមានចំណាប់អារម្មណ៍ឬមានអារម្មណ៍ផ្សារភ្ជាប់ផ្សេងពីនេះចំពោះបេតិកភណ្ឌវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច។ ការពិគ្រោះយោបល់នឹងត្រូវធ្វើឡើងដោយអនុលោមតាមបទដ្ឋានបរិស្ថាន និងសង្គមទី ១០ នៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមសម្រាប់គម្រោងដំណាក់កាលទី ៣។ សូមធ្វើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យដើម្បីកំណត់អត្តសញ្ញាណបេតិកភណ្ឌវប្បធម៌ដែលអាចរងផលប៉ះពាល់ដោយសារគម្រោងពិចារណាពីសារៈសំខាន់នៃបេតិកភណ្ឌទាំងនោះ ប៉ាន់ប្រមាណហានិភ័យ និងផលប៉ះពាល់ និងរិះរកជម្រើសបញ្ចៀស និងសម្រាលផលប៉ះពាល់។ ការពិគ្រោះយោបល់ត្រូវរក្សាការសម្ងាត់ទៅតាមភាពចាំបាច់ រួមទាំងការគោរពព័ត៌មានសម្ងាត់ដែលទាក់ទងនឹងប្រពៃណី។

31. ក្រោមបទដ្ឋានបរិស្ថាន និងសង្គមទី ៨ របស់ធនាគារពិភពលោក ការការពារបេតិកភណ្ឌវប្បធម៌ត្រូវបានរំពឹងថានឹងទាមទារនូវជំហានតាមលំដាប់លំដោយ ដូចជា ការពិនិត្យបឋម ការប្រមូលទិន្នន័យដើមគ្រា ការរៀបចំលក្ខខណ្ឌយោង ការប៉ាន់ប្រមាណផលប៉ះពាល់ និងការបង្កើតវិធានការកាត់បន្ថយផលប៉ះពាល់ និងផែនការគ្រប់គ្រង។ ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ផ្តល់ការណែនាំពីដំណើរការនេះសម្រាប់គម្រោងដំណាក់កាលទី ៣។

## ៥.បេតិកភណ្ឌវប្បធម៌ក្នុងតំបន់គម្រោង

32. បទដ្ឋានបរិស្ថាន និងសង្គមទី ៨ តម្រូវឱ្យមានវិធានការកាត់បន្ថយការបាត់បង់ ឬការផ្លាស់ប្តូរតំបន់ដែលមានសារៈសំខាន់ផ្នែកវប្បធម៌។ ការខូចខាត ឬការបំផ្លិចបំផ្លាញទីតាំងរកឃើញថ្មីដោយចៃដន្យ អាចបណ្តាលមកពីសកម្មភាពពាក់ព័ន្ធនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រខ្នាតតូច។ បទដ្ឋានបរិស្ថាន និងសង្គមទី ៨ ត្រូវបានបំផុសឡើង ព្រោះសកម្មភាពដែលស្នើឡើងក្នុងគម្រោងដំណាក់កាលទី ៣ អាចប៉ះពាល់ដោយផ្ទាល់



DRAFT

ឬដោយប្រយោលលើធនធានវប្បធម៌រូបវន្ត និងអរូបីរបស់សហគមន៍ជនជាតិដើមភាគតិច។ ជនជាតិដើមភាគតិចច្រើន តែមានទំនាក់ទំនងជិតស្និទ្ធទៅនឹងតំបន់ព្រៃ រួមទាំងទំនាក់ទំនងផ្នែកជំនឿ។ ចំណុចទាំងនេះអាចប្រែប្រួលទៅតាម សហគមន៍ ព្រោះអនុក្រុមផ្សេងៗ និងមនុស្សមួយជំនាន់ៗមានតម្លៃ និងការបកស្រាយខុសគ្នាលើបេតិកភណ្ឌវប្បធម៌។ ឧ. ស្ត្រី និងក្មេងស្រី អាចមានអារម្មណ៍ជាប់ជំពាក់ជាមួយលំហ និងបេតិកភណ្ឌវប្បធម៌របស់ខ្លួន ខ្លាំងជាងបុរស និងក្មេងប្រុស។ អាចមានករណីដោយឡែកៗដែលសកម្មភាពផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច រំខានដល់ទីតាំងព្រៃសក្តិសិទ្ធិដែលអ្នកភូមិបានកំណត់[1]។ ក្រៅពីនេះ អាចមានការរកឃើញទីតាំងបុរាណវត្ថុ ប្រវត្តិសាស្រ្ត ឬទីតាំងវប្បធម៌ថ្មី ក្នុងពេលឈូសឆាយ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រខ្នាតតូច។

33. គម្រោងដំណាក់កាលទី ៣ នឹងពាក់ព័ន្ធនឹងទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ ជនជាតិដើមភាគតិចក្នុងតំបន់ភូមិសាស្រ្តដ៏ធំនៅភាគឦសាននៃប្រទេសកម្ពុជា ដែលសំបូរដោយសហគមន៍ជនជាតិដើមភាគតិច។ ភាគច្រើននៃជនជាតិភាគតិច ដូចជា កួយ ព្នង ទំពួន ចារ៉ាយ គ្រឹង ស្មៀង ព្រៅ កាវ៉ែត ក្រោល មិល កាចក់ ខោញ លុន រស់នៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះ។ សហគមន៍ទាំងនេះសំបូរដោយ បេតិកភណ្ឌវប្បធម៌រូបី និងអរូបី ដែលត្រូវកំណត់អត្តសញ្ញាណទៅតាមករណីនីមួយៗ នៅពេលធ្វើការពិនិត្យបឋម (មើលទម្រង់ពិនិត្យបឋមក្នុងក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម) និងការរៀបចំផែនការបែបចូលរួមដែលត្រូវបាន ដាក់បញ្ចូលក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងដំណើរការរៀបចំផែនការសម្រាប់ការវិនិយោគលើបរចិញ្ចឹមជីវិត និងហេដ្ឋារចនាសម្ព័ន្ធសហគមន៍។ ដំណើរការនេះមានរៀបរាប់លម្អិតក្នុងក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច។

34. សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ការអនុវត្តបទដ្ឋានបរិស្ថាន និងសង្គមទី ៨ នឹងស៊ីសង្វាក់គ្នានឹងបទដ្ឋានបរិស្ថាន និងសង្គមទី ៧។ ប្រសិនបើលក្ខខណ្ឌតម្រូវនៃបទដ្ឋានបរិស្ថាន និងសង្គមទី ៨ ខុសពីបទប្បញ្ញត្តិក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៧ ដែលអាចអនុវត្តបានចំពោះបេតិកភណ្ឌរបស់ជនជាតិដើមភាគតិច ត្រូវអនុវត្តតាមបទប្បញ្ញត្តិក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៧។ ក្របខណ្ឌរៀបចំផែនការជនជាតិភាគតិច ផ្តល់ការណែនាំជារួមស្តីពីការកាត់បន្ថយហានិភ័យដែលអាចធ្វើឱ្យប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិច រួមទាំងបេតិកភណ្ឌវប្បធម៌ និងរបរចិញ្ចឹមជីវិតរបស់ពួកគេ។ ក្របខណ្ឌនេះកំណត់ពីដំណើរការច្បាស់លាស់នៃការ ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដូចតទៅ៖ ជំហានទី ១ ការទទួលស្គាល់ជនជាតិដើមភាគតិច, ជំហានទី ២ ៖ ការផ្តល់ស្ថានភាពស្របច្បាប់ជាសហគមន៍ជនជាតិដើមភាគតិច ការរៀបចំ និងការ បំពេញពាក្យសុំចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងការដាក់ពាក្យសុំចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងជំហានទី ៣ ៖ ដំណើរការចុះបញ្ជីប័ណ្ណកម្មសិទ្ធិ

[1]ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មិនសុទ្ធតែធ្វើឱ្យមានការបាត់បង់លទ្ធភាពរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការប្រើប្រាស់ព្រៃឈើឡើយ ព្រោះផលប៉ះពាល់ទាំងនេះគួរត្រូវបានបញ្ចៀសតាមរយៈការរៀបចំផែនការបែបចូលរួម និងការអនុវត្តក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ និងក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច។

ដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ វត្ថុមាន និងផលប៉ះពាល់ដែលអាចកើតមានឡើងលើបេតិកភណ្ឌវប្បធម៌ នឹងត្រូវបានកំណត់រកនៅដំណាក់កាលនីមួយៗនៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ជាពិសេសជំហានទី ២ និងទី ៣។ ផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ (CHMP) នឹងត្រូវបានរៀបចំឡើងនៅតាមទីតាំងជាក់លាក់សម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងដំណើរការកំណត់អត្តសញ្ញាណ និងដាក់ពាក្យសុំ។ ឧបសម្ព័ន្ធ ១ នៃឯកសារនេះបង្ហាញពីទម្រង់ផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌។

35. ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ឆ្លុះបញ្ចាំងពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដែលរួមមានការគូសផែនទីដីលំនៅដ្ឋាន ដីបម្រុង ដីព្រៃជំនឿ និងដីព្រៃកប់ខ្មោច និងរៀបចំជាស្រេចនូវវិធានការសម្រាប់ការការពារតំបន់ទាំងនេះ ព្រមទាំងធានាលទ្ធភាពចេញចូលតំបន់ទាំងនេះផងដែរ។ ប្រព័ន្ធប្រើប្រាស់ដីបែបប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ជាពិសេសកសិកម្មពនេចរណ៍ត្រូវបានចាត់ទុកជាបេតិកភណ្ឌវប្បធម៌ និងជាផ្នែកមួយនៃដីទាំង ៥ ប្រភេទដែលត្រូវកំណត់អត្តសញ្ញាណ និងគូសផែនទីក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ជាយូរណាស់មកហើយដែលការអនុវត្តទាំងនេះរួមចំណែកដល់របរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព សន្តិសុខស្បៀង ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព និងការអភិរក្ស និងពង្រឹងជីវចម្រុះ។

36. ក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិចសម្រាប់គម្រោងដំណាក់កាលទី ៣ កំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចដែលអាចរងផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមានដោយសារគម្រោង ដើម្បីដាក់បញ្ចូល ១) សហគមន៍ជនជាតិដើមភាគតិចដែលជាក្រុមគោលដៅ សម្រាប់ទទួលបានជំនួយលើការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងសកម្មភាពអភិវឌ្ឍន៍ជនបទលើដីសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និង ២) សហគមន៍ជនជាតិដើមភាគតិចដែលអាចមានវត្តមានក្នុងតំបន់ដែលត្រូវអនុវត្តសម្បទានដីសង្គមកិច្ច (មិនថាត្រូវបានទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ ឬយ៉ាងណានោះទេ)។ ក្នុងករណីណាមួយក៏ដោយ សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់អាចរួមបញ្ចូលទាំងអ្នកទទួលផលពីគម្រោង (សមាជិកសហគមន៍ជនជាតិដើមភាគតិចដែលទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងអ្នកទទួលបានដីធ្លីក្នុងសម្បទានដីសង្គមកិច្ច) និងអ្នកផ្សេងទៀតដែលរស់នៅក្នុងសហគមន៍ជនជាតិដើមភាគតិចក្នុងតំបន់នោះ ឬមិនទទួលបានប័ណ្ណកម្មសិទ្ធិពីសម្បទានដីសង្គមកិច្ច។ ប្រសិនបើជនជាតិដើមភាគតិច និងក្រុមគ្រួសាររបស់ពួកគេទទួលរងផលប៉ះពាល់អវិជ្ជមាន ពួកគេនឹងប្រើប្រាស់សិទ្ធិដូចពលរដ្ឋទូទៅដើម្បីដាក់បណ្តឹងតាមរយៈយន្តការដោះស្រាយបណ្តឹងតវ៉ារបស់គម្រោង។

37. ទីតាំង និងវត្ថុបេតិកភណ្ឌវប្បធម៌រូបីដែលបន្សល់ពីសម័យអង្គរ និងមុនអង្គរក្នុងប្រទេសកម្ពុជា ស្ថិតនៅរាយប៉ាយតាមដងទន្លេក្រោម ប្រភពទឹក និងផ្លូវធ្វើដំណើរសំខាន់ៗ ប៉ុន្តែមានតិចនៅតាមតំបន់ព្រៃ។ សម្បទានដីសង្គមកិច្ចភាគច្រើនដែលត្រូវទទួលបានជំនួយពីគម្រោងដំណាក់កាលទី ៣ ត្រូវបានរំពឹងថានឹងស្ថិតលើដីដែលធ្លាប់ជាព្រៃពីមុន ឬនៅ

DRAFT

តែជាដីព្រៃដែលរេចរិល។ វត្ថុរកឃើញដែលកំពុងមាន និងដែលអាចមានក្នុងតំបន់គម្រោង ត្រូវបានរំពឹងថានឹងមានចំនួនតិច។ ក្នុងករណីប្រទះឃើញវត្ថុ យើងនឹងអនុវត្ត "នីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ" (មើលខ្លឹមសារលម្អិតក្នុងផ្នែក ៥.២ ខាងក្រោម)។

38. កំណត់ត្រាបង្ហាញថាមានប្រាសាទបុរាណតែ ៤ ប៉ុណ្ណោះក្នុងខេត្តក្រចេះ និងកំពង់ចាម និងសុទ្ធតែស្ថិតនៅតាមដងទន្លេមេគង្គ។

- ប្រាសាទ ២ ក្នុងខេត្តក្រចេះ ៖ ក្នុងឃុំស្រែជិះ និងឃុំខ្សឹម
- ប្រាសាទ ២ ក្នុងខេត្តកំពង់ចាម ៖ ក្នុងឃុំជប់ និងឃុំមួយផ្សេងទៀត។

39. ស្រុកសំបូរក្នុងខេត្តក្រចេះក៏ជាទីតាំងទីក្រុងមុនសម័យអង្គរដ៏ធំមួយផងដែរ។

40. ខេត្តកំពង់ធំមានទីតាំងសក្តានុពលថ្មីយ៉ាងតិច ២ និងទីតាំងសម្បទានដីសង្គមកិច្ចចាស់មួយ ដែលត្រូវទទួលបានជំនួយពីគម្រោងដំណាក់កាលទី ៣។ ខុសពីខេត្ត ២ ផ្សេងទៀត ខេត្តកំពង់ធំសំបូរដោយទីតាំងពាក់ព័ន្ធនឹងសម័យអង្គរ និងសម័យមុនអង្គររួមទាំងទីតាំងក្នុងតំបន់ព្រៃ។

41. ស្រុកមេមត់ក្នុងខេត្តត្បូងឃ្មុំមានបេតិកភណ្ឌបុរេប្រវត្តិដ៏គួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹង "ការងារកាយ និងចាក់ដី" ដូចជា ទំនប់ទឹកធំៗរាងជារង្វង់នៅលើដីដែលគេប្រើសម្រាប់ការពារភូមិរាងជារង្វង់នៅយុគថ្ម។ ទីតាំងភាគច្រើននៅកម្ពុជាដែលត្រូវបានកំណត់អត្តសញ្ញាណរហូតមកទល់បច្ចុប្បន្ន ស្ថិតក្នុងស្រុកមេមត់។ ក្នុងចំណោមទីតាំងទាំង ២៨ នេះ ទីតាំងមួយស្ថិតក្នុងឃុំជាំក្រវៀន ដែលជាឃុំសាកល្បង។ ផ្នូរបុរេប្រវត្តិដែលមានវត្ថុបុរាណ ត្រូវបានរកឃើញនៅទីតាំង ៦ ក្នុងស្រុកពញាក្រែកដែលនៅជិតស្រុកមេមត់។ មជ្ឈមណ្ឌល និងសារមន្ទីរបុរាណវិទ្យាមេមត់ដែលទទួលបានជំនួយពីគម្រោងអាល្លឺម៉ង់ បានជួយអភិរក្សទីតាំងទាំងនេះ។

42. របាយស្មើគ្នានៃទីតាំងសម្បទានដីសង្គមកិច្ចត្រូវបានរំពឹងថានឹងស្ថិតក្នុង ឬនៅជុំវិញទីតាំងសម័យសង្គ្រាម ឬជម្លោះពីមុន។ នេះអាចជាហេតុផលមួយដែលធ្វើឱ្យប្រជាជនរស់នៅរប៉ាត់រប៉ាយ។ ខណៈដែលបច្ចុប្បន្នទីតាំងទាំងនេះគ្មានលក្ខណៈសម្បត្តិជាទីតាំងបេតិកភណ្ឌវប្បធម៌ គួរកត់សម្គាល់ពីវត្តមានទីតាំងទាំងនេះនៅលើដីធ្លីពាក់ព័ន្ធដែលគ្រួសារថ្មីនឹងមកតាំងទីលំនៅក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

# ៦.វិធានការការពារបេតិកភណ្ឌវប្បធម៌ក្នុងគម្រោងដំណាក់កាលទី ៣

## ៦.១ វិធីសាស្ត្រ

43. គម្រោងដំណាក់កាលទី ៣ ពាក់ព័ន្ធនឹងសហគមន៍ជនជាតិដើមភាគតិច។ ក្នុងនោះ ក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច (IPPF) ត្រូវបានរៀបចំឡើងឱ្យបន្សុីគ្នានឹងបទដ្ឋានបរិស្ថាន និងសង្គមទី ៧ របស់ធនាគារពិភពលោក។ បន្ថែមលើលក្ខខណ្ឌតម្រូវនៃក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ និងបទដ្ឋានបរិស្ថាន និងសង្គមទី ៨ របស់



DRAFT

ធនាគារពិភពលោក យើងនឹងអនុវត្តតាមវិធីសាស្ត្រមានស្រាប់របស់ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធរួមទាំងមន្ទីរវប្បធម៌ ក្នុងការរៀបចំក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌវប្បធម៌នៅតាមទីតាំងដាក់លាក់សម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ហើយនឹងត្រូវបានដាក់ជូនធនាគារពិភពលោកពិនិត្យ និងអនុម័ត មុននឹងយកទៅអនុវត្ត។

44. យើងនឹងអនុវត្តវិធីសាស្ត្រខាងក្រោមសម្រាប់ការកំណត់អត្តសញ្ញាណ និងដោះស្រាយផលប៉ះពាល់ដែលអាចកើតមានឡើងចំពោះបេតិកភណ្ឌវប្បធម៌រូបី និងអរូបី ក្នុងគម្រោងដំណាក់កាលទី ៣។ វិធីសាស្ត្រនេះនឹងត្រូវបានឆ្លុះបញ្ចាំងក្នុងសៀវភៅណែនាំការអនុវត្តគម្រោង និងលក្ខខណ្ឌយោងនៃជំនួយបច្ចេកទេស ៖

**បេតិកភណ្ឌវប្បធម៌ក្នុងគម្រោងដំណាក់កាលទី ៣**

គម្រោងដំណាក់កាលទី ៣ ផ្តោតការយកចិត្តទុកដាក់លើបេតិកភណ្ឌវប្បធម៌ ( ទាំងរូបី និងអរូបី ) ក្នុងឃុំ និងសហគមន៍ជនជាតិដើមភាគតិចទាំងអស់ដែលស្ថិតក្រោមគម្រោងនេះ។ រាជរដ្ឋាភិបាលកម្ពុជាដែលតំណាងដោយស្ថាប័នដឹកនាំការអនុវត្តគម្រោង និងស្ថាប័នអនុវត្តន៍គម្រោងដំណាក់កាលទី ៣ នឹងបញ្ចៀសផលប៉ះពាល់លើបេតិកភណ្ឌវប្បធម៌ដែលកើតចេញពីសកម្មភាពគម្រោង។ ប្រសិនបើមិនអាចបញ្ចៀសផលប៉ះពាល់បាន រដ្ឋាភិបាលនឹងកំណត់រក និងអនុវត្តវិធានការនានាសំដៅកាត់បន្ថយផលប៉ះពាល់លើបេតិកភណ្ឌវប្បធម៌ជាអតិបរមាដោយអនុលោមតាមឋានានុក្រមសម្រាលផលប៉ះពាល់។ ផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌នឹងត្រូវបានបង្កើតឡើងសម្រាប់ទីតាំងពាក់ព័ន្ធ ទៅតាមភាពចាំបាច់។ ផែនការនេះនឹងរួមបញ្ចូលក្របខណ្ឌពេលវេលាអនុវត្តន៍ និងការប៉ាន់ស្មានពីតម្រូវការធនធានសម្រាប់វិធានការសម្រាលផលប៉ះពាល់។ ផែនការនេះអាចជាផែនការដាច់ដោយឡែក ឬជាផ្នែកមួយនៃផែនការផ្សេងទៀត ( ឧ. ផែនការសម្រាប់ជនជាតិដើមភាគតិច ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម) អាស្រ័យលើលក្ខណៈ និងវិសាលភាពនៃហានិភ័យ និងផលប៉ះពាល់របស់អនុគម្រោង។

នៅដំណាក់កាលណាមួយនៃវដ្តគម្រោងដំណាក់កាលទី៣ ដែលអាចបង្កផលប៉ះពាល់លើបេតិកភណ្ឌវប្បធម៌ ស្ថាប័នដឹកនាំការអនុវត្ត និងស្ថាប័នអនុវត្តន៍គម្រោងនឹង ក ) ដាក់ពង្រាយអ្នកជំនាញសម្រាប់ជួយដល់ការកំណត់អត្តសញ្ញាណ និងការការពារបេតិកភណ្ឌវប្បធម៌ និង ខ ) ធានាថា ការអនុវត្តល្អជាអន្តរជាតិសម្រាប់ការសិក្សាតាមមូលដ្ឋាន ការចងក្រងឯកសារ និងការការពារបេតិកភណ្ឌវប្បធម៌ត្រូវបានយកមកអនុវត្តដោយក្រុមហ៊ុនម៉ៅការ និងភាគីតតីយជនផ្សេងទៀត។ ឧ. នីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យកំណត់ពីការគ្រប់គ្រងការរកឃើញដោយចៃដន្យនូវវត្ថុបុរាណក្នុងសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង ដែលនឹងត្រូវបានដាក់បញ្ចូលក្នុងកិច្ចសន្យាទាំងអស់ដែលពាក់ព័ន្ធនឹងសកម្មភាពសាងសង់របស់គម្រោង។

ស្ថាប័នដឹកនាំការអនុវត្ត និងស្ថាប័នអនុវត្តន៍គម្រោងនឹងធានាការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់ដោយអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងក្របខណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក ជា

DRAFT

ពិសេសបទដ្ឋានបរិស្ថាន និងសង្គមទី ១០ ដើម្បីរៀបចំ និងអនុវត្តវិធានការសមស្របសម្រាប់ការបញ្ចៀស ឬ កាត់បន្ថយផលប៉ះពាល់លើបេតិកភណ្ឌវប្បធម៌ ដោយពិចារណាពីលក្ខខណ្ឌតម្រូវបន្ថែមដែលត្រូវបានកំណត់សម្រាប់ប្រភេទបេតិកភណ្ឌវប្បធម៌ជាក់លាក់។ នឹងមានការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធក្នុងពេលវាយតម្លៃបរិស្ថាន និងសង្គមនៅតាមទីតាំងជាក់លាក់សម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលបានកំណត់រួចរាល់ សម្រាប់បេតិកភណ្ឌវប្បធម៌ដែលគេដឹងថាមាន ឬងាយនឹងប្រទះឃើញក្នុងពេលអនុវត្តគម្រោង តាមរយៈការអនុវត្តបទដ្ឋានបរិស្ថាន និងសង្គមទី ១០។ អ្នកពាក់ព័ន្ធរួមមានសហគមន៍ដែលរងផលប៉ះពាល់ដោយសារគម្រោង អាជ្ញាធរជាតិ ឬអាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកជំនាញមួយចំនួន រួមទាំងអង្គការបេតិកភណ្ឌវប្បធម៌អន្តរជាតិ។

ការបកស្រាយនិយមន័យបេតិកភណ្ឌវប្បធម៌ក្នុងសហគមន៍មូលដ្ឋាន និងអាចខុសពីបទដ្ឋានជាតិ ឬការយល់ឃើញរបស់មនុស្សក្រៅសហគមន៍ នឹងត្រូវបានសិក្សាស្វែងយល់ និងពិចារណាដិតដល់។ ស្ត្រី និងក្មេងស្រីមានអារម្មណ៍ជាប់ជំពាក់ចំពោះលំហ និងបេតិកភណ្ឌរបស់ខ្លួន ខុសពីបុរស និងក្មេងប្រុស។ ការសិក្សាស្វែងយល់នឹងពិចារណាពីផលប៉ះពាល់របស់គម្រោងលើក្រុមមនុស្ស និងអនុក្រុមផ្សេងៗក្នុងសហគមន៍។ ដូច្នេះ ដំណើរការកំណត់អត្តសញ្ញាណ ការស្វែងយល់ពីផលប៉ះពាល់ ការរៀបចំវិធានការសមស្របសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌ នឹងពិចារណាពីចំណុចខុសគ្នាទាំងនេះ។

## ៦.២ វិធានការជាក់លាក់

45. វិធានការមួយចំនួនដើម្បីបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់របស់សកម្មភាពគម្រោងលើបេតិកភណ្ឌវប្បធម៌ រួមមាននីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ វិធានការសម្រាប់ការពង្រឹងសមត្ថភាពរបស់ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវលើការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ការបង្កើតប្រព័ន្ធត្រួតពិនិត្យដើម្បីតាមដានវឌ្ឍនភាព និងប្រសិទ្ធភាពនៃសកម្មភាពទាំងនេះ ការរៀបចំកាលវិភាគអនុវត្តន៍ និងកញ្ចប់ថវិកាចាំបាច់សម្រាប់វិធានការកាត់បន្ថយផលប៉ះពាល់ដែលបានកំណត់និងការរៀបចំកាតាឡុកសម្គាល់វត្ថុដែលត្រូវបានរកឃើញ។នៅពេលមានវត្តមានសហគមន៍ជនជាតិដើមភាគតិចក្នុងទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលពាក់ព័ន្ធនឹងគម្រោងយើងនឹងអនុវត្តតាមលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក និងក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិចរបស់គម្រោង។ ក្រៅពីនេះ នឹងមានការគូសផែនទីដោយមានការចូលរួម និងការគ្រោងលំហាត់នានាសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិលើទីតាំងសម្បទានដីសង្គមកិច្ច និងសកម្មភាពចិញ្ចឹមជីវិត ដើម្បីកំណត់អត្តសញ្ញាណបេតិកភណ្ឌវប្បធម៌រូបី និងអរូបីរបស់សហគមន៍ជនជាតិដើមភាគតិច។

DRAFT

## វិធានការសម្រាប់បេតិកភណ្ឌវប្បធម៌ក្នុងគម្រោងដំណាក់កាលទី ៣

1. ការិយាល័យគម្រោងដំណាក់កាលទី ៣ ថ្នាក់ខេត្ត មានច្បាប់ចម្លងផែនទីបញ្ជីសារពើភណ្ឌបេតិកភណ្ឌថ្នាក់ជាតិពេញលេញ (ទទួលបានពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ)។ ការិយាល័យនេះតែងធ្វើរបាយការណ៍ប្រចាំឆ្នាំដាក់ជូនមន្ទីរវប្បធម៌ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌនេះ។
2. ផែនទីស្តីពីការប្រើប្រាស់ដីឃុំ លើកឡើងពីបេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ និងបេតិកភណ្ឌជនជាតិដើមភាគតិច ដោយផ្អែកលើគោលការណ៍ណែនាំថ្មីៗ/ការអនុវត្តល្អបំផុតក្នុងមូលដ្ឋានដែលទទួលបានពីកម្មវិធី SEILA។
3. ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ ៖ សារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌជនជាតិដើមភាគតិចត្រូវបានពន្យល់ និងពិគ្រោះយោបល់ក្នុងកិច្ចប្រជុំសហគមន៍ដើម្បីកំណត់អត្តសញ្ញាណបេតិកភណ្ឌវប្បធម៌និងស្វែងយល់ថាតើមានការព្រួយបារម្ភពីផលប៉ះពាល់អវិជ្ជមានរបស់គម្រោងលើបេតិកភណ្ឌវប្បធម៌របស់ពួកគេ ឬទេ។
4. ទីតាំងបេតិកភណ្ឌវប្បធម៌រូបី និងអរូបី ត្រូវបានកំណត់អត្តសញ្ញាណយ៉ាងហ្មត់ចត់ មុនពេលចុះវាស់វែងលម្អិត (ការកំណត់អត្តសញ្ញាណដីធ្លី)។ កំណត់សម្គាល់ពីការពិនិត្យបឋមនៅថ្នាក់ឃុំត្រូវបានរៀបចំឡើងនៅតាមទីតាំងនីមួយៗសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅឆ្នាំដំបូង។ ផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌តាមទីតាំងនឹងត្រូវបានរៀបចំឡើងសម្រាប់បេតិកភណ្ឌវប្បធម៌រូបី និងអរូបី បន្ទាប់ពីការកំណត់អត្តសញ្ញាណទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច (មើលឧបសម្ព័ន្ធ ក ៖ គំរូឯកសារផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌)។
5. បទប្បញ្ញត្តិសម្រាប់ប្រភេទបេតិកភណ្ឌវប្បធម៌ជាក់លាក់ដែលរួមបញ្ចូលទីតាំងបុរាណវត្ថុ និងវត្ថុបុរាណសំណង់ប្រវត្តិសាស្ត្រ លក្ខណៈធម្មជាតិដែលមានសារៈសំខាន់ផ្នែកវប្បធម៌ និងបេតិកភណ្ឌវប្បធម៌ដែលជាចលនវត្ថុ។
6. តំណាងភូមិ និងសហគមន៍ជនជាតិដើមភាគតិច ចូលរួមក្នុងសកម្មភាពវាស់វែងជាក់ស្តែងដើម្បីបង្ហាញពីទីតាំងបន្ថែមទៀត ដូចជា ផ្នូរ និងព្រៃ ឬដើមឈើជំនឿ (ការកំណត់អត្តសញ្ញាណដីធ្លី)។
7. ក្នុងករណីដែលទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច ស្ថិតក្នុងបណ្តាខេត្តដែលសំបូរដោយបេតិកភណ្ឌវប្បធម៌ ត្រូវមានការវាយតម្លៃដោយអ្នកជំនាញដែលមានគុណវុឌ្ឍិ។
8. ក្នុងករណីប្រទះឃើញវត្ថុមានតម្លៃដោយចៃដន្យ ត្រូវអនុវត្ត "នីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ" (ឧបសម្ព័ន្ធ ខ)។
9. រៀបចំវិធានការសម្រាប់ការពង្រឹងសមត្ថភាពរបស់អាជ្ញាធរថ្នាក់ជាតិ (ស្ថាប័នដឹកនាំការអនុវត្តគម្រោង ស្ថាប័នអនុវត្តន៍គម្រោង និងក្រសួងពាក់ព័ន្ធ) និងថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវលើការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ដែលរងផលប៉ះពាល់ដោយសារគម្រោង។

DRAFT

46. វិធានការទី ១ ធានាលទ្ធភាពរកបានទិន្នន័យបញ្ជីសារពើភណ្ឌបច្ចុប្បន្នភាពនៅថ្នាក់ខេត្ត។ វិធានការទី ២ មានគោលបំណងបញ្ជ្រាបចំណាប់អារម្មណ៍ចំពោះបេតិកភណ្ឌវប្បធម៌ទាំងរូបី និងអរូបីក្នុងគម្រោងដំណាក់កាលទី ៣ នៅថ្នាក់ក្រោមជាតិ។

47. វិធានការទី ៣ ( ស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង ) ពាក់ព័ន្ធនឹងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងជំរុញឱ្យពួកគេចូលរួមក្នុងការកំណត់អត្តសញ្ញាណ និងកំណត់តម្លៃចំពោះបេតិកភណ្ឌវប្បធម៌ដែលរងផលប៉ះពាល់ដោយសារគម្រោង ការវាយតម្លៃផលប៉ះពាល់ដែលអាចកើតមានឡើង និងការរិះរកជម្រើសបញ្ចៀស និងជម្រើសកាត់បន្ថយផលប៉ះពាល់។ ស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង ធានាការដាក់បញ្ចូល និងកិច្ចសហប្រតិបត្តិការរបស់អ្នកពាក់ព័ន្ធផ្សេងៗតាមរយៈកិច្ចសន្ទនាជាមួយអាជ្ញាធរមានសមត្ថកិច្ច រួមទាំងអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធដើម្បីរៀបចំមធ្យោបាយមានប្រសិទ្ធភាពសម្រាប់លើកឡើងពីទស្សនៈ និងការព្រួយបារម្ភរបស់អ្នកពាក់ព័ន្ធ និងជំរុញការចូលរួមរបស់ពួកគេក្នុងការការពារ និងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌។ ការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ដោយសារគម្រោងនឹងធានាការស៊ើបអង្កេត និងស្វែងយល់ពីការយល់ឃើញរបស់សហគមន៍ស្តីពីបេតិកភណ្ឌវប្បធម៌ ដែលអាចនឹងខុសពីបទដ្ឋានថ្នាក់ជាតិ ឬការយល់ឃើញរបស់មនុស្សនៅក្រៅសហគមន៍ និងធានាការពិចារណាពីការយល់ឃើញរបស់ស្ត្រី និងក្មេងស្រីដែលខុសពីការយល់ឃើញរបស់បុរស និងក្មេងស្រី។

48. វិធានការទី ៤ ពិនិត្យថាតើត្រូវមានការពិនិត្យបឋម ឬទេ។ យើងនឹងប្រើប្រាស់កំណត់សម្គាល់ការពិនិត្យបឋមដោយផ្អែកលើទម្រង់ដែលមានភ្ជាប់។ អ្នកទទួលខុសត្រូវគឺមន្ត្រីបង្គោលផ្នែកសង្គម និងបរិស្ថាននៃការិយាល័យគម្រោងដំណាក់កាលទី ៣ នៅថ្នាក់ខេត្ត។ កំណត់សម្គាល់ការពិនិត្យបឋមនឹងត្រូវបានពិនិត្យឡើងវិញក្រោយបញ្ចប់ការអនុវត្តគម្រោងឆ្នាំទី ១។ ប្រសិនបើទីតាំងទាំងអស់ដែលត្រូវបានកំណត់អត្តសញ្ញាណរួចរាល់ ស្ថិតក្រោមការការពារស្រាប់ដោយបញ្ជីសារពើភណ្ឌថ្នាក់ខេត្ត ហើយក្រុមប្រឹក្សាឃុំទាំងអស់ទទួលបានព័ត៌មានគ្រប់គ្រាន់ពីនីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ មិនចាំបាច់ធ្វើកំណត់សម្គាល់ការពិនិត្យបឋមបន្ថែមនៅឆ្នាំបន្តបន្ទាប់ឡើយ។

49. វិធានការទី ៥ ចែងពីលក្ខខណ្ឌតម្រូវឱ្យស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង ធានាការរួមបញ្ចូល និងកិច្ចសហប្រតិបត្តិការរបស់អ្នកពាក់ព័ន្ធសំដៅអភិរក្សប្រភេទបេតិកភណ្ឌវប្បធម៌ជាក់លាក់ រួមទាំងទីតាំងបុរាណវត្ថុ និងវត្ថុបុរាណ សំណង់ប្រវត្តិសាស្ត្រ លក្ខណៈធម្មជាតិដែលមានសារៈសំខាន់ផ្នែកវប្បធម៌ និងបេតិកភណ្ឌវប្បធម៌ដែលជាចលនវត្ថុ ដែលត្រូវមានវិធានការអភិរក្សបន្ថែមទៀត។

50. វិធានការទី៦ គូសបញ្ជាក់ពីសារៈសំខាន់នៃការគូសផែនទីដោយមានការចូលរួមក្នុងការកំណត់អត្តសញ្ញាណទីតាំង និងវត្ថុដែលមានសារៈសំខាន់ផ្នែកវប្បធម៌។ នៅពេលទីតាំងត្រូវបានកំណត់អត្តសញ្ញាណរួចរាល់ និងរកឃើញទីតាំង និងវត្ថុដែលអាចមានសារៈសំខាន់ផ្នែកវប្បធម៌ នឹងមានការរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌សម្រាប់ទីតាំងជាក់លាក់នីមួយៗ។ ផែនការនេះមានក្របខណ្ឌពេលវេលាអនុវត្តន៍ និងការប៉ាន់ស្មានតម្រូវការធនធានសម្រាប់វិធានការកាត់បន្ថយផលប៉ះពាល់នីមួយៗ។ ផែនការនេះអាចជាផែនការដាច់ដោយឡែក ឬជាផ្នែកមួយនៃផែនការ



DRAFT

ផ្សេងទៀត (ផែនការសម្រាប់ជនជាតិដើមភាគតិច ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម) អាស្រ័យលើលក្ខណៈ និងវិសាលភាពនៃហានិភ័យ និងផលប៉ះពាល់របស់អនុគម្រោង។

51. វិធានការទី ៧ ពាក់ព័ន្ធនឹងលទ្ធភាពនៃការជ្រើសរើសយកខេត្តកំពង់ធំ ឬខេត្តមួយផ្សេងទៀតដែលសំបូរដោយបេតិកភណ្ឌវប្បធម៌ ធ្វើជាទីតាំងគម្រោង។ ប្រសិនបើខេត្តណាមួយត្រូវជ្រើសរើសយក អ្នកជំនាញដែលមានគុណវុឌ្ឍិនឹងធ្វើការវាយតម្លៃលម្អិតលើទីតាំងនានា និងដាក់របាយការណ៍ជាក់លាក់ និងវិធានការការពារ។

52. វិធានការទី ៨ (ក្នុងករណីប្រទះឃើញវត្ថុមានតម្លៃ) នឹងអនុវត្ត "នីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ" (ឧបសម្ព័ន្ធ ខ ៖ បេតិកភណ្ឌវប្បធម៌-នីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ)។

53. វិធានការទី ៩ រៀបរាប់ពីលក្ខខណ្ឌតម្រូវឱ្យមានការបណ្តុះបណ្តាល និងការបង្កើនការយល់ដឹងដើម្បីអាចអនុវត្តក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ដោយប្រសិទ្ធភាព។ ស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង និងក្រុមហ៊ុនម៉ៅការត្រូវធ្វើយ៉ាងណាឱ្យបុគ្គលិកគម្រោងទាំងអស់ ដែលទទួលខុសត្រូវលើការការពារបេតិកភណ្ឌវប្បធម៌មានសមត្ថភាព និងទទួលបានការបណ្តុះបណ្តាល និងការកសាងការយល់ដឹងចាំបាច់។ ការបណ្តុះបណ្តាលមានគោលបំណងបង្កើនការយល់ដឹងជាមូលដ្ឋានស្តីពីទីតាំងដែលគេស្គាល់ក្នុងតំបន់គម្រោង និងពន្យល់ពីការកំណត់អត្តសញ្ញាណ វត្ថុបេតិកភណ្ឌវប្បធម៌ដែលត្រូវបានរកឃើញ បញ្ឈប់ការងារ និងនីតិវិធីរាយការណ៍ដោយផ្អែកតាមនីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ។ ការបណ្តុះបណ្តាលនឹងបង្កើនការយល់ដឹងពីបេតិកភណ្ឌវប្បធម៌រូបី និងអរូបី ទំនៀមទម្លាប់ក្នុងមូលដ្ឋាន និងបទដ្ឋានប្រពៃណី រួមទាំងរបៀបប្រតិបត្តិខ្លួនក្នុងក្រុមវប្បធម៌ផ្សេងៗរបស់ជនជាតិដើមភាគតិច។

DRAFT

## ឧបសម្ព័ន្ធ ក ៖ គំរូឯកសារផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌

ផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ (CHMP) ជាផែនការដាច់ដោយឡែក និងផ្អែកតាមទីតាំងដែលអាចមានហានិភ័យ និងផលប៉ះពាល់ចំពោះបេតិកភណ្ឌវប្បធម៌។ ការរៀបចំផែនការនេះជាលក្ខខណ្ឌចាំបាច់សម្រាប់ទីតាំងដែលមានលទ្ធភាពខ្ពស់នៃការរកឃើញវត្ថុមានតម្លៃដោយចៃដន្យ ឬបេតិកភណ្ឌវប្បធម៌ដែលបានកំណត់អត្តសញ្ញាណរួចរាល់ និងត្រូវការការពារ។ ខាងក្រោមនេះជាទម្រង់ឯកសារផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ៖

1. សេចក្តីផ្តើមខ្លី និងគោលបំណង
    1.1. សេចក្តីសង្ខេបពីបេតិកភណ្ឌវប្បធម៌រូបី និងអរូបីនៅទីតាំងអនុគម្រោង
    1.2. គោលបំណងនៃផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌
    1.3. វិសាលភាពនៃផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌

2. លក្ខខណ្ឌស្តង់ដារ និងលក្ខខណ្ឌច្បាប់
    2.1. លក្ខខណ្ឌច្បាប់ជាតិ
    2.2. ស្តង់ដារ និងគោលការណ៍ណែនាំអន្តរជាតិ
    2.3. យុត្តាធិការនៃថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

    ស្ថាប័នសំខាន់ៗដែលមានតួនាទីគ្រប់គ្រងបេតិកភណ្ឌវប្បធម៌គឺក្រសួង និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរជាតិអប្សរា ក្រសួង និងមន្ទីរអភិវឌ្ឍន៍ជនបទ ក្រសួង និងមន្ទីរបរិស្ថាន ស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង រដ្ឋាភិបាលថ្នាក់ខេត្ត និងស្រុក និងក្រុមប្រឹក្សាឃុំ។

3. ការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌
    3.1. ការវាយតម្លៃពីសារៈសំខាន់នៃធនធានបេតិកភណ្ឌវប្បធម៌
    3.2. ការពិគ្រោះយោបល់ជាមួយសហគមន៍
    3.3. ការពិគ្រោះយោបល់ជាមួយអាជ្ញាធរពាក់ព័ន្ធ
    3.4. ការចុះវាស់វែងបេតិកភណ្ឌវប្បធម៌

        ការចុះវាស់វែងបេតិកភណ្ឌវប្បធម៌គួរតែជាផ្នែកមួយនៃការរៀបចំផែនការប្រើប្រាស់ដីធ្លី និងត្រូវរួមបញ្ចូល ៖ បញ្ជីទ្រព្យសម្បត្តិបេតិកភណ្ឌវប្បធម៌នានា ទីតាំង និងការអនុវត្តសំខាន់ៗក្នុងទំនៀមទម្លាប់/ប្រពៃណី ការយល់ដឹងពីទ្រព្យសម្បត្តិ ទីតាំង ឬការអនុវត្តនីមួយៗដែលបានកំណត់អត្តសញ្ញាណ កូអរដោនេ GPS សម្រាប់សម្បត្តិបេតិកភណ្ឌវប្បធម៌ និងទីតាំងដែលបានកំណត់អត្តសញ្ញាណ ការបញ្ជាក់ពីឧបសគ្គ/ភាពងាយរងគ្រោះដែលបានកំណត់រក និងរបៀបបញ្ចៀសផលប៉ះពាល់លើទ្រព្យសម្បត្តិ/ទីតាំងបេតិកភណ្ឌទាំងនោះ។

DRAFT

3.5. វិធានការគ្រប់គ្រង និងការពារបេតិកភណ្ឌវប្បធម៌
3.6. ការអនុវត្ត និងក្របខណ្ឌពេលវេលា

4. ស្ថាប័នពាក់ព័ន្ធ តួនាទី និងការទទួលខុសត្រូវ
   4.1. តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង
   4.2. តួនាទី និងការទទួលខុសត្រូវរបស់ក្រុមហ៊ុនម៉ៅការ

5. ការបណ្តុះបណ្តាល ការកសាងការយល់ដឹង និងធនធានចាំបាច់
   - ការបណ្តុះបណ្តាលការយល់ដឹងសម្រាប់បុគ្គលិកទាំងអស់ដែលអាចប្រទះឃើញធនធានបេតិកភណ្ឌវប្បធម៌រូបី និងអរូបីក្នុងសកម្មភាពប្រចាំថ្ងៃ
   - ការបណ្តុះបណ្តាលពីបេតិកភណ្ឌវប្បធម៌ជាក់លាក់ សម្រាប់អ្នកឯកទេសលើផ្នែកមិនពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌ ដែលត្រូវបានចាត់តាំងជាអ្នកត្រួតពិនិត្យ។

6. ការរាយការណ៍ និងការជូនដំណឹង
   6.1. ការរាយការណ៍ពីការចុះវាស់វែងបេតិកភណ្ឌវប្បធម៌ដោយក្រុមហ៊ុនម៉ៅការ ( 3.4. )
   6.2. ការរាយការណ៍ពីវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ ( ឧបសម្ព័ន្ធ ខ )

7. យន្តការដោះស្រាយបណ្តឹងតវ៉ា
8. ថវិកា

DRAFT

## ឧបសម្ព័ន្ធ ខ ៖ គំរូឯកសារនីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ

### 1 គោលបំណង វត្ថុបំណង និងវិសាលភាព

សកម្មភាពពាក់ព័ន្ធនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ព្រមទាំងការគាំទ្ររបរចិញ្ចឹមជីវិតក្រោមគម្រោងដំណាក់កាលទី ៣ អាចធ្វើឱ្យមានការផ្លាស់ប្តូរបេតិកភណ្ឌវប្បធម៌រូបី ឬអរូបី ទីតាំងវប្បធម៌ និងបុរាណវត្ថុដែលគេមិនស្គាល់ ឬគ្មានកំណត់ត្រា។ គម្រោងដំណាក់កាលទី ៣ នឹងបង្កើតនីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ ដើម្បីកំណត់ពីដំណាក់កាលសម្រាប់ការគ្រប់គ្រងវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ បន្ទាប់ពីការរកឃើញ។ ស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោងនឹងខិតខំធ្វើយ៉ាងណាឱ្យក្រុមហ៊ុនម៉ៅការ និងអ្នកជំនាញផ្នែករបរចិញ្ចឹមជីវិត យល់ច្បាស់ពីលទ្ធភាពដែលពួកគេអាចរកឃើញវត្ថុរកឃើញដែលគេមិនស្គាល់ និងដឹងពីរបៀបគ្រប់គ្រង។ នីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យមានគោលបំណង ៖

- កំណត់ពីជំហានដែលត្រូវអនុវត្តក្នុងការគ្រប់គ្រងការប្រទះឃើញទីតាំងដែលគេមិនធ្លាប់ស្គាល់រួមទាំងការអភិរក្ស និងការធ្វើប្រព្រឹត្តកម្មសមស្របលើវត្ថុរកឃើញទាំងនេះ ក៏ដូចជាកាត់បន្ថយការរំខានដល់កាលវិភាគសាងសង់។
- ពង្រឹងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាតិពាក់ព័ន្ធ និងលក្ខខណ្ឌតម្រូវផ្សេងទៀត។

ស្ថាប័នដឹកនាំការអនុវត្ត និងស្ថាប័នអនុវត្តន៍គម្រោងនឹងធានាថា ក្រុមហ៊ុនម៉ៅការ/ក្រុមហ៊ុនម៉ៅការបន្តក្នុងគម្រោងដំណាក់កាលទី ៣ អនុវត្តតាមនីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យនៅគ្រប់ទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។

### 2 នីតិវិធី និងការអនុវត្ត

#### 2.1 នីតិវិធីរៀបចំផែនការ

**ការពិគ្រោះយោបល់ ៖** ស្ថាប័នដឹកនាំការអនុវត្ត និងស្ថាប័នអនុវត្តន៍គម្រោងនឹងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ ដូចជា ក្រសួងពាក់ព័ន្ធនៅថ្នាក់ជាតិ មន្ទីរបច្ចេកទេសពាក់ព័ន្ធ និងអាជ្ញាធរស្រុក ដើម្បីសម្រេចយកនីតិវិធីចំពោះវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ។

**មន្ទីរពិសោធន៍ និងការគាំទ្រផ្សេងទៀត ៖** ក្រោមជំនួយរបស់អ្នកជំនាញផ្នែកវប្បធម៌ ស្ថាប័នដឹកនាំការអនុវត្ត និងស្ថាប័នអនុវត្តន៍គម្រោងនឹងរៀបចំ និងអនុវត្តវគ្គបណ្តុះបណ្តាល និងការកសាងការយល់ដឹងពីបេតិកភណ្ឌវប្បធម៌ (ឧ. ការបណ្តុះបណ្តាលមូលដ្ឋានស្តីពីការកំណត់អត្តសញ្ញាណទីតាំង និងវត្ថុដែលពាក់ព័ន្ធនឹងទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច រួមទាំងសហគមន៍ជនជាតិដើមភាគតិចដែលមានសារៈសំខាន់ផ្នែកវប្បធម៌)។ វគ្គបណ្តុះបណ្តាល និងការកសាងការយល់ដឹងត្រូវរៀបចំឡើង



DRAFT

សម្រាប់ស្ថាប័នអនុវត្តន៍គម្រោងទាំងអស់នៅថ្នាក់ក្រោមជាតិ ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្ត មុននឹងពួកគេចូលរួមក្នុងការងារ/សកម្មភាពចិញ្ចឹមជីវិត។

## 2.2 ការអនុវត្ត

### 2.2.1 ការពិនិត្យតាមដាន

ការពិនិត្យតាមដានត្រូវធ្វើឡើងដោយបុគ្គលិកដែលមានការបណ្តុះបណ្តាលសមស្រប ដើម្បីកំណត់ពីសារៈសំខាន់នៃវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ ដោយអនុលោមតាមនិយមន័យដែលបានកំណត់ក្នុងក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌវប្បធម៌របស់គម្រោងដំណាក់កាលទី ៣ និងអនុវត្តតាមជំហានសម្រាប់វត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ ( ឧបសម្ព័ន្ធ ១ )។

<table>
<tr><td colspan="3">
ឧបសម្ព័ន្ធ ១ ៖ ជំហានសម្រាប់វត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ<br>
<br>
• ច្បាប់ចម្លងនៃទម្រង់របាយការណ៍ស្តីពីវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ សម្រាប់បង្ហាញជូនស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង និងតំណាងថ្នាក់ខេត្ត<br>
• ការផ្ទៀងផ្ទាត់ទម្រង់របាយការណ៍នីមួយៗធៀបនឹងវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យនីមួយៗ<br>
• វត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ ត្រូវបានវេចខ្ចប់ និងបិទស្លាកសមស្រប។<br>
• បញ្ជីសារពើភណ្ឌនៃវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ ត្រូវបានដាក់នៅខាងក្នុងប្រអប់បិទជិត។<br>
• បញ្ហាសេសសល់ដែលពាក់ព័ន្ធនឹងចំណុចណាមួយ ឬចំណុចទាំងអស់ខាងលើ ត្រូវបានដោះស្រាយ។<br>
• ស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង ឬតំណាងថ្នាក់ខេត្ត ទទួលយកការប្រគល់វត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យពីក្រុមហ៊ុនម៉ៅការទៅឱ្យមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈពាក់ព័ន្ធ។
</td></tr>
<tr><td>តំណាងក្រុមហ៊ុនម៉ៅការ</td><td>តំណាងស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង</td><td>តំណាងថ្នាក់ខេត្ត</td></tr>
<tr><td>ឈ្មោះ</td><td>ឈ្មោះ</td><td>ឈ្មោះ</td></tr>
<tr><td>ហត្ថលេខា</td><td>ហត្ថលេខា</td><td>ហត្ថលេខា</td></tr>
<tr><td>កាលបរិច្ឆេទ</td><td>កាលបរិច្ឆេទ</td><td>កាលបរិច្ឆេទ</td></tr>
</table>

### 2.2.2 បញ្ឈប់ការងារ

a ) បន្ទាប់ពីបានកំណត់អត្តសញ្ញាណទីតាំងដែលមានវត្ថុបេតិកភណ្ឌវប្បធម៌ ក្រុមហ៊ុនម៉ៅការ ឬក្រុមហ៊ុនម៉ៅការបន្ត ត្រូវបញ្ឈប់ការងារក្នុងចម្ងាយសមស្របពីទីតាំងនោះ។

b ) ក្រុមហ៊ុនម៉ៅការ/ក្រុមហ៊ុនម៉ៅការបន្ត ត្រូវស្នើឱ្យស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង និងថ្នាក់ខេត្តចុះទៅទីតាំងដើម្បីធ្វើការកំណត់យ៉ាងហ្មត់ចត់ពីសារៈសំខាន់នៃវត្ថុដែលរកឃើញនោះ។

c ) ក្នុងករណីរកឃើញទីតាំងដែលអាចមានសារៈសំខាន់ខ្លាំងផ្នែកវប្បធម៌ ក្រុមហ៊ុនម៉ៅការ/ក្រុមហ៊ុនម៉ៅការបន្ត ត្រូវកំណត់ព្រំប្រទល់ និងធានាសន្តិសុខតំបន់នោះ។

d ) ស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ និងក្រុមហ៊ុនម៉ៅការ ត្រូវវាយតម្លៃទីតាំង ឬវត្ថុនានា ដោយអនុលោមតាមនីតិវិធីដែលកំណត់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

DRAFT

### 2.2.3 ការគ្រប់គ្រងវត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ

ក្នុងករណីដែលទីតាំងដែលមានវត្ថុរកឃើញដោយចៃដន្យ ជាទីតាំងដែលមានសារៈសំខាន់ខ្លាំងផ្នែកវប្បធម៌ ក្រុមហ៊ុនម៉ៅការ និងស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង ត្រូវសហការគ្នាកំណត់ពីលក្ខខណ្ឌតម្រូវសម្រាប់ការជំរុញការចូលរួមរបស់សហគមន៍ ដោយអនុលោមតាមបទដ្ឋានបរិស្ថាន និងសង្គមទី ១០។ ក្រុមនេះនឹងស្វែងរក និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដែលរងផលប៉ះពាល់ រួចបង្កើតវិធានការសមស្រប។

**ជម្រើសនៃការគ្រប់គ្រង ៖** ជម្រើសគ្រប់គ្រងខាងក្រោមនឹងត្រូវបានលើកមកពិចារណា។

- **ការបញ្ចៀស ៖** ការកាត់បន្ថយផលប៉ះពាល់លើទីតាំង តាមរយៈការរចនាគម្រោងឡើងវិញទាំងស្រុង ឬដោយផ្នែក ឬការជម្លៀសចេញ គួរតែជាជម្រើសសមស្របសម្រាប់ការគ្រប់គ្រងធនធានវប្បធម៌។
- **ការគ្រប់គ្រងក្នុងទីតាំង ៖** ជម្រើសនេះរួមមានការអនុវត្តវិធានការការពារទីតាំង។ វិធានការការពារសមស្របនឹងត្រូវបានកំណត់រក និងសម្រេចយកដោយស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង ក្រុមហ៊ុនម៉ៅការ មន្ទីរវប្បធម៌ និងអាជ្ញាធរមូលដ្ឋាននៅតាមទីតាំងជាក់លាក់។
- **ការបំផ្លាញចោល ៖** ប្រសិនបើទីតាំងត្រូវបានវាយតម្លៃថាមិនសូវមានសារៈសំខាន់ផ្នែកវប្បធម៌ ទីតាំងនោះអាចនឹងត្រូវបានបំផ្លាញចោល បន្ទាប់ពីការធ្វើកំណត់ត្រារូបថតពេញលេញ និងការបំពេញទម្រង់របាយការណ៍វត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យ។

## 3 ការរាយការណ៍

នឹងមានការរាយការណ៍ពីទីតាំងបេតិកភណ្ឌវប្បធម៌ទាំងអស់ ទៅស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង និងថ្នាក់ខេត្ត និងថ្នាក់ជាតិ ក្នុងរបាយការណ៍ប្រចាំខែរបស់ក្រុមហ៊ុនម៉ៅការ។ របាយការណ៍នោះរួមមាន ៖

- ព័ត៌មានបច្ចុប្បន្នភាពស្តីពីសូចនាការអនុវត្តន៍ការងារសំខាន់ៗ
- ឧប្បត្តិហេតុនៃការរំខានដល់ទីតាំងបេតិកភណ្ឌវប្បធម៌ដែលគេស្គាល់
- ទីតាំងបេតិកភណ្ឌវប្បធម៌ទាំងអស់ត្រូវបានកំណត់អត្តសញ្ញាណ ដោយញែកវត្ថុរកឃើញដែលគេស្គាល់ និងវត្ថុរកឃើញដោយចៃដន្យ។
- វត្ថុមានតម្លៃដែលរកឃើញដោយចៃដន្យទាំងអស់។ល។